ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង**
**ការិយាល័យអប់រំ យុវជន និងកីឡា ស្រុកសំឡូត**
**អង្គភាព: វិទ្យាល័យសំឡូត**

*លេខកូដសាលា: ០២១១០៧០៧៩០១*

*លេខទូរស័ព្ទ : ០៩៥៨៦៨៨៣៨/០៦៨៨៦៨៨៣៨*

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន
# ឆ្នាំ ២០១៩-២០២៣




## ឆ្នាំ ២០២០

# អារម្ភកថា

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនឆ្នាំ២០១៩-២០២៣ ជាស្នាដៃថ្មីមួយរបស់សាលាវិទ្យាល័យសំឡូត ដែលពុំធ្លាប់បានរៀនចំការ ងារនេះនាពេលកន្លងមក។ ផែនការនេះ រៀបចំឡើងក្នុងគោលបំណងប្រមូលផ្តុំនូវយុទ្ធសាស្ត្រ និងសកម្មភាពចម្បងៗដែលត្រូវអនុវត្ត រយៈពេល៥ ឆ្នាំ និងធ្វើការព្យាករណ៍ថវិកាសម្រាប់គាំទ្រយុទ្ធសាស្ត្រ និងសកម្មភាពដែលបានលើកឡើង ក៏ដូចជាយន្តការនៃការពិនិត្យ តាមដាន និងវាយតម្លៃ ដើម្បីធ្វើយ៉ាងណាឱ្យការអនុវត្តផែនការ ត្រូវទៅតាមគន្លង ឆ្ពោះទៅសម្រេចវត្ថុបំណង និងចំណុចដៅដែលបានដាក់ចេញ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនឆ្នាំ២០១៩-២០២៣ ជាផែនទីបង្ហាញផ្លូវរយៈពេល ០៥ ឆ្នាំ ដែលជាបង្អែកដ៏រឹងមាំក្នុងការធ្វើឱ្យមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រថវិកា ៣ ឆ្នាំ រំកិល  ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិសាលារៀនប្រចាំឆ្នាំ ដែលបានបង្ហាញពីទំនាក់ទំនងពិតប្រាកដរវាងក្របខណ្ឌយុទ្ធសាស្ត្រ សកម្មភាព ព្រមទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ និងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការបង្កើនលទ្ធភាពទទួលបានការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ដើម្បីគាំទ្រដល់ការងារនេះ សាលានឹងបន្តអនុវត្តការពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល សហគមន៍ មាតាបិតាសិស្ស ដៃគូអភិវឌ្ឍ និងអង្គការ មិនមែនរដ្ឋាភិបាលជាច្រើនទៀត។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនឆ្នាំ២០១៩-២០២៣  ត្រូវបានរៀបចំឡើងក្រោមបរិបទនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា២០១៨-២០២៣ និងការវិភាគលើលទ្ធផលនៃការបំពេញការងារកន្លងមក ដោយមានការចូលរួម ពីលោកគ្រូអ្នកគ្រូ មាតាបិតាសិស្ស និង  គណៈកម្មការគ្រប់គ្រងសាលារៀន។

យើងខ្ញុំជានាយក គណៈកម្មការគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូទាំងអស់នៃសាលាវិទ្យាល័យសំឡូត សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំយុវជន និងកីឡា ស្រុក ជានិច្ចកាលតែងបានយកចិត្តទុកដាក់ជួយលើផ្នែកបច្ចេកទេសក្នុងដំណើរការរៀបចំរហូតបានសម្រេចចេញ ជារូបរាងឡើង។

ថ្ងៃ....................ខែ ...............ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

................., ថ្ងៃទី .....    ខែ ............ឆ្នាំ២០១៩

**នាយកសាលា**

# មាតិកា

*លេខទំព័រ*

**១-សេចក្តីផ្តើម** ........................................ ៣
**២-ប្រវត្តិសាលារៀន** ........................................ ៣
**៣-ចក្ខុវិស័យ** ........................................ ៣
**៤-បេសកកម្ម** ........................................ ៤
**៥-ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមចម្បងៗ** ........................................ ៤
**៦-គោលបំណង** ........................................ ១៣
**៧-ចំណុចដៅប្រចាំឆ្នាំរបស់សាលារៀន** ........................................ ១៣
**៨-យុទ្ធសាស្ត្រ និងសកម្មភាព** ........................................ ១៤
**៩-តម្រូវការហិរញ្ញប្បទាន** ........................................ ២០
**១១-យន្តការពិនិត្យតាមដាននិងវាយតម្លៃ** ........................................ ២១
**១១-តារាងឧបសម្ព័ន្ធ** ........................................ ២១

## ១.សេចក្តីផ្តើម

វិទ្យាល័យសំឡូតគឺជាសាលាមួយ ដែលទើបតែធ្វើសមាហរណកម្មចុងក្រោយគេក្នុងចំណោមក្រុង និងស្រុកទាំង១៤ នៃខេត្តបាត់ដំបង មានចម្ងាយ១គីឡូម៉ែត្រ ពីការិយាល័យអប់រំយុវជន និងកីឡាស្រុក និងចម្ងាយ៧៨ គីឡូម៉ែត្រពីមន្ទីរអប់រំយុវជន និងកីឡាខេត្ត។សាលានេះមានអនុវិទ្យាល័យចំណុះចំនួន ៦និងបឋមសិក្សាចំណុះចំនួន ៨ ហើយសាលាបានទទួលសិស្សមកពី៧ ឃុំ និង៤៩ភូមិ ទូទាំងស្រុក សំឡូត ដែលក្នុងនោះមានប្រជាជនរស់នៅសរុប៩,៤៨៤គ្រួសារស្មើនឹងមនុស្សរាយ៤០,៨៩៧នាក់ក្នុងនោះ ស្រី ២០,៥៩១នាក់គិតក្នុងឆ្នាំ២០១២។ នៅក្នុងឆ្នាំសិក្សា២០១៨-២០១៩ វិទ្យាល័យសំឡូតបានទទួលសិស្សឱ្យចូលរៀន បានចំនួន៩៥០ នាក់ ស្រី៤៩៥ នាក់ និងបានរៀបចំជា ២០ថ្នាក់ ដែលមានពីថ្នាក់ទី៧ រហូតដល់ថ្នាក់ទី១២។ សាលារៀននេះ មានបុគ្គលិក សរុប៤២ នាក់ ស្រី១៧ នាក់ ក្នុងនោះមាននាយក ១ នាក់ និង នាយករង ២ នាក់ មានអគារសិក្សាសរុប៣ខ្នង មាន១៥ បន្ទប់ សម្រាប់បម្រើឱ្យការសិក្សារបស់សិស្ស។ ចំណែកឯលទ្ធផលសិក្សាក្នុងឆ្នាំសិក្សា(២០១៨-២០១៩) នេះ សិស្សដែលបានប្រឡងជាប់មធ្យមសិក្សាបឋមភូមិមានចំនួនៈ នាក់ ស្រី នាក់ ត្រូវជាភាគរយ និងសិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិមានចំនួនៈ ៥៩នាក់ ស្រី នាក់ ត្រូវជា ៦១ភាគរយ។ ដោយសារតែកំណើនសិស្សចេះតែកើនឡើងធ្វើឲ្យវិទ្យាល័យសំឡូតក្លាយទៅជាមជ្ឈមណ្ឌលបណ្តុះ បណ្តាលធនធានមនុស្សមួយយ៉ាងសំខាន់បើទោះជាមានការខ្វះខាត និងជួបប្រទះនូវការលំបាកច្រើនយ៉ាងណាក្តី ក៏ថ្នាក់ដឹកនាំសាលានិងបុគ្គលិកសិក្សាទាំងអស់បានខិតខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្ត ដើម្បីប្រែក្លាយតំបន់ដាច់ស្រយាលមួយ ឲ្យមានភាពប្រសើរឡើងតាមរយៈការអភិវឌ្ឍន៍ធនធានមនុស្សនិងស្របតាមយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលតាមរយៈការអប់រំប្រកបដោយប្រសិទ្ធភាព និងចេរភាព។ទន្ទឹមនឹងនេះដែរ ដើម្បីធ្វើឲ្យវិទ្យាល័យសំឡូតក្លាយទៅជាកន្លែងបណ្តុះបណ្តាលធនធានមនុស្សដ៏មានប្រសិទ្ធភាពនោះការអភិវឌ្ឍន៍សាលារៀនគឺជាកត្តាដ៏សំខាន់មួយ ក្នុងដំណើរការបណ្តុះបណ្តាល និងផ្តល់នូវចំណេះដឹង។ ដូច្នេះដើម្បីឲ្យការអភិវឌ្ឍន៍ទទួលបានលទ្ធផលល្អប្រសើរ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនពិតជាចាំបាច់បំផុត ព្រោះវាជាផែនទីចង្អុលបង្ហាញ និងជាត្រីវិស័យមួយសម្រាប់អោយអ្នកគ្រប់គ្រង និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តន៏ និងប្រតិបត្តិតាម ហើយវាជាអ្នកកំណត់នូវភាពជោគជ័យ ឬបរាជ័យរបស់អង្គភាពនិងប្រៀបបានជាម៉ែត្រសម្រាប់វាស់វែង ប្រៀបធៀបលទ្ធផលនៃការអនុវត្តន៍ជាក់ស្តែង ទៅនឹងលទ្ធផលដែលបានរំពឹងទុករបស់អង្គភាព។

ជាមួយគ្នានេះដែរ តាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនឆ្នាំ២០១៩-២០២៣ នេះ ក្នុងនាមគណៈគ្រប់គ្រងសាលាវិទ្យាល័យសំឡូត លោកគ្រូ/អ្នកគ្រូ សហគមន៍ និងអ្នកពាក់ព័ន្ធទាំងអស់ មានជំនឿយ៉ាងមុតមាំថា ការខឹតខំប្រឹងប្រែងអនុវត្តន៍ផែនការនេះនឹងទទួលបានជោគជ័យ គឺធ្វើយ៉ាងណាឱ្យកុមារដែលសិក្សានៅមធ្យមសិក្សា ទាំងអស់ទទួលបានការអប់រំរៀនសូត្រ ឆ្លើយតបទៅនឹងគោលនយោបាយនៅក្នុងផែនការយុទ្ធ សាស្ត្រវិស័យអប់រំខេត្ត២០១៩-២០២៣ គឺធានាការអប់រំដែលមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើក កម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដែលធ្វើឱ្យសហគមន៍ពេញចិត្តពេញថ្លើម និងមានទំនុកចិត្តមកលើការផ្តល់សេវារបស់សាលារៀន។ ជាពិសេសជាងនេះទៀត គឺដើម្បីធានាបាននូវការអប់រំមួយដែលមានលក្ខណៈស្តង់ដារ និងមានភាពប្រកួតប្រជែងខ្ពស់ក្នុងបរិបថសាកលភាវូបនីយកម្ម នៅក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោក។

## ២.សាវតាសាលារៀន

វិទ្យាល័យសំឡូត បានបង្កើតឡើងក្នុងឆ្នាំ ២០០៥មានទីតាំង ស្ថិតនៅក្នុងភូមិ អូរស្នួត ឃុំតាសាញ ស្រុក សំឡូត ខេត្ត បាត់ដំបង លើផ្ទៃដីសរុប ៤០,០០០ ម៉ែត្រក្រឡា។ ដោយសារតែតម្រូវការធនធានមនុស្សជាកត្តាដ៏ចាំបាច់ក្នុងការអភិវឌ្ឍន៏និងដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលនៅក្នុងឆ្នាំ២០០១ អជ្ញាធរគ្រប់លំដាប់ថ្នាក់និងសហគមន៏ នៅក្នុងស្រុកសំឡូតទាំងមូលបានពុះពារ បង្កើតឡើងនៅសាលាអនុវិទ្យាល័យដំបូងគេដែលមានឈ្មោះថា អនុវិទ្យាល័យសំឡូត ។ អនុវិទ្យាល័យសំឡូតមានអាគារសិក្សា១ខ្នង ស្មើនឹង ៥ បន្ទប់ ដែលជាអំណោយ **ឯកឧត្តម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។នៅឆ្នាំ២០០១ សាលានេះមានសិស្សចំនួយ១១៥ នាក់ ស្រី ៣៤ នាក់ ដែលមកពីសាលាបឋមសិក្សាក្នុងឃុំទាំង៧។នៅឆ្នាំសិក្សា ២០០២-២០០៣ សិស្សបានកើនឡើង ២៦៦ នាក់ និងស្រី ៩៥ នាក់ ដែលមកពីសាលាបឋមចំណុះចំនួន៥ ដោយសារតែឃុំពីរទៀតមានចម្ងាយឆ្ងាយ និងស្ថានភាពផ្លូវលំបាកខ្លាំងធ្វើឲ្យសិស្សពុំមានលទ្ធភាពធ្វើដំណើរមករៀនទេនិងមួយផ្នែកទៀត គឺកត្តាជីវភាពខ្វះខាត។នៅឆ្នាំសិក្សា ២០០៣-២០០៤ សាលាបានទទួលសិស្សចំនួន២៧៧ នាក់ ស្រីចំនួន១០៦ នាក់ ដែលជាចំនួនមួយដែលមានការកើនឡើងតិចតួច ពីព្រោះតែការកាត់បន្ថយនូវសាលាបឋមសិក្សាចំណុះដែលមានចម្ងាយឆ្ងាយពីសាលាគឺ ឃុំស៊ុង និងឃុំ សំឡូត។ ហើយក្នុងឆ្នាំសិក្សា

២០០៤-២០០៥ អនុវិទ្យាល័យសំឡូត ក៏បានពង្រីកខ្លួនទៅជាវិទ្យាល័យសំឡូត ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់សម្រាប់សិស្សដែលបានប្រឡងជាប់មធ្យមសិក្សាបឋមភូមិ ហើយត្រូវបន្តទៅមធ្យមសិក្សាទុតិយភូមិទៀត។នៅក្នុងឆ្នាំសិក្សា ២០០៤-២០០៥ មានសិស្សចំនួន ៣២៩ នាក់ ហើយក្នុងនោះស្រី ១២៥ នាក់ សិស្សថ្នាក់ទី១០ មានចំនួន ៣៧នាក់ ស្រី ១៩ នាក់ ស្មើនឹង១ ថ្នាក់។ក្នុងឆ្នាំសិក្សា ២០០៥-២០០៦ សិស្សបានកើនឡើង ៤០១ នាក់ ស្រី១៣៧ នាក់ ក្នុងនោះសិស្សនៅមធ្យមសិក្សាទុតិយភូមិចំនួន ២ថ្នាក់ ស្មើនឹង ៧៦នាក់ ស្រី ២៤ នាក់។ កំនើនសិស្សបានកើនឡើងយ៉ាងឆាប់រហ័សនៅឆ្នាំសិក្សា ២០០៦-២០០៧ មានចំនួន ៥២៨ នាក់ ស្រី ២១៥ នាក់ ហើយក៏ជាឆ្នាំសិក្សាដំបូងដែល វិទ្យាល័យសំឡូតមានសិស្សថ្នាក់ទី ១២ ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដែលសិស្សត្រូវប្រឡងមានចំនួន២៤ នាក់ ស្រី ១២ នាក់។ជាលទ្ធផលសិស្សបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិមានចំនួន ២០ នាក់ ស្រី ៩នាក់។ ក្នុងបវេសនកាល ២០០៧-២០០៨ សិស្សសរុបមានចំនួន ៧៤១ នាក់ ស្រី ២៩៦ នាក់ ក្នុងនោះសិស្សមធ្យមសិក្សាទុតិយភូមិមាន ៦ថ្នាក់ និងបឋមភូមិមាន៩ថ្នាក់។ម្យ៉ាងវិញទៀតនៅក្នុងចំណោមសិស្សដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានសិស្សចំនួន ៤នាក់ ដែលបានទទួលអាហារូបករណ៍ សម្រាប់ការសិក្សានៅសាកលវិទ្យាល័យរយៈពេល៤ឆ្នាំដោយឥតគិតថ្លៃ។ នៅក្នុងឆ្នាំសិក្សា ២០០៨-២០០៩ សិស្សបានកើនដល់៨៨០នាក់ ស្រី៣៧០នាក់ និងក្នុងឆ្នាំសិក្សា២០១៥-១៦សិស្សមានចំនួន ៦៦៤នាក់ ស្រី៣២៧នាក់។ ដោយសារតែកំណើនសិស្សចេះតែកើនឡើងធ្វើឲ្យវិទ្យាល័យសំឡូតក្លាយទៅជាមជ្ឈមណ្ឌលបណ្ដុះបណ្ដាលធនធានមនុស្សមួយយ៉ាងសំខាន់ បើទោះជាមានការខ្វះខាត និងជួបប្រទះនូវការលំបាកច្រើនយ៉ាងណាក្ដី ក៏ថ្នាក់ដឹកនាំសាលានិងបុគ្គលិកសិក្សាទាំងអស់បានខិតខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្ត ដើម្បីប្រែក្លាយតំបន់ដាច់ស្រយាលមួយ ឲ្យមានភាពប្រសើរឡើងតាមរយៈការអភិវឌ្ឍន៍ធនធានមនុស្ស និងស្របតាមយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលតាមរយៈការអប់រំប្រកបដោយប្រសិទ្ធភាព និងចេរភាព។ទន្ទឹមនឹងនេះដែរ ដើម្បីធ្វើឲ្យវិទ្យាល័យសំឡូតក្លាយទៅជាកន្លែងបណ្ដុះបណ្ដាលធនធានមនុស្សដ៏មានប្រសិទ្ធភាពនោះ ការអភិវឌ្ឍន៍សាលារៀនគឺជាកត្តាដ៏សំខាន់មួយ ក្នុងដំណើរការបណ្ដុះបណ្ដាល និងផ្ដល់នូវចំណេះដឹង។ ដូច្នេះដើម្បីឲ្យការអភិវឌ្ឍន៍ទទួលបានលទ្ធផលល្អប្រសើរ គម្រោងអភិវឌ្ឍន៍សាលារៀនពិតជាចាំបាច់បំផុត ព្រោះវាជាផែនទីចង្អុលបង្ហាញ និងជាត្រីវិស័យមួយសម្រាប់ អ្នកគ្រប់គ្រង និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តន៍ប្រតិបត្តិតាម ហើយវាជាអ្នកកំណត់នូវភាពជោគជ័យ ឬបរាជ័យរបស់អង្គភាព និងប្រៀបបានជាម៉ែត្រសម្រាប់វាស់វែង ប្រៀបធៀបលទ្ធផលនៃការអនុវត្តន៍ជាក់ស្ដែង ទៅនឹងលទ្ធផលដែលបានរំពឹងទុករបស់អង្គភាព។

## ៣. ចក្ខុវិស័យៈ

ជាសាលារៀនឈានមុខគេក្នុងការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព គុណធម៌ និងនវានុវត្តន៍។

ដើម្បីសម្រេចនូវចក្ខុវិស័យដែលបានរៀបចំឡើង គណៈគ្រប់គ្រងសាលារៀន បានគិតគូរច្បាស់លាស់លើការរៀបចំបេសកកម្មដ៏ធំធេងនេះដែរ ពីព្រោះបេសកកម្មនេះ វាពាក់ព័ន្ធខ្លាំងទៅនឹងយន្តការនៃការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍន៍សាលារៀន ដែលជាបច្ច័យល្អ ឬបច្ច័យអាក្រក់ គឺអាស្រ័យទៅលើវានេះឯង។

## ៤.បេសកកម្មៈ

ពង្រឹងអភិបាលកិច្ចល្អលើការងារគ្រប់គ្រងគ្រប់ផ្នែក ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព ទំនាក់ទំនងល្អ និងសុខដុមនីយកម្ម។

## ៥. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមចម្បងៗ

### ក.ស្ថានភាពបច្ចុប្បន្ន

១.ការគ្រប់គ្រង និងដឹកនាំសាលារៀនៈ

- បំណែងចែកភារកិច្ចគណៈគ្រប់គ្រង/គ្រូបង្រៀនៈ ត្រូវបានរៀបចំស្របតាមនិយាមរបស់ក្រសួងអប់រំ និងផ្អែកលើអតីតភាព ស្នាដៃ និងកម្រិតថ្នាក់។
- ការរៀបចំផែនការគ្រប់ប្រភេទៈ មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ រួមមាន: ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ផែនការថវិកា៣ឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំជាដើម។



រូបភាពទី១: សកម្មភាពប្រជុំធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

- ការរៀបចំរបាយការណ៍គ្រប់ប្រភេទ៖ បានរៀបចំតាមប្រភេទ និងក្រូណូត្រឹមត្រូវ
- ការងារទំនាក់ទំនង៖ តែងតែបានប្រជុំជាមួយអាណាព្យាបាលសិស្សគ្រប់ថ្នាក់ និងអជ្ញាធរពាក់ព័ន្ធ ដើម្បីបង្កើតក្រុមផ្តល់ព័ត៌មានតាមឃុំទូទាំងស្រុកសំឡូត។
- ការគ្រប់គ្រង/ប្រើប្រាស់ថវិកាគ្រប់ប្រភេទ៖ បានរៀបចំគណៈកម្មការគ្រប់គ្រងការប្រើប្រាស់ថវិកា និងមានការចូលរួមប្រើប្រាស់ និងត្រួតពិនិត្យពីគណៈកម្មការគ្រប់គ្រងសាលារៀន ថ្នាក់រៀន គ្រូ និងក្រុមប្រឹក្សាយុវជនជាតំណាងសិស្ស ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំយុវជន និងកីឡាខេត្តបាត់ដំបង**
**ការិយាល័យអប់រំ យុវជន និងកីឡា**
**ស្រុក សំឡូត**
**វិទ្យាល័យសំឡូត**
លេខ៖ .................វិ.សឡ

**សេចក្តីសម្រេច**
**ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន(គ.ម.ស)**
**សម្រាប់ឆ្នាំសិក្សា ៖ ២០២០-២០២១**

**យោង៖** -ខ្លឹមសារសៀវភៅគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈឆ្នាំ២០១៨ របស់នាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា ។

-លិខិតលេខៈ**១០០៤៣ សហវ.អថ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៨** របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីករណីសំណើសុំពិនិត្យ និងសម្រេចលើសេចក្តីព្រាងសៀវភៅណែនាំ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់អនុវត្តមូលនិធិកែលម្អសាលារៀន ដើម្បីប្រើប្រាស់នៅក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីឆ្នាំ២០១៩ តទៅ ។

-កំណត់ហេតុប្រជុំរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន(គ.ម.ស) នាថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០២០ របស់វិទ្យាល័យសំឡូត (ភ្ជាប់បញ្ជីវត្តមានប្រជុំជូនភ្ជាប់) ។

**ប្រការ១៖** សមាសភាព ដូចមានរាយនាមខាងក្រោមនេះ ត្រូវបានជ្រើសតាំងជា **គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន(គ.ម.ស) សម្រាប់ឆ្នាំសិក្សា ៖ ២០២០-២០២១ ។**

1. លោក ហួត សុខុម នាយកសាលា ជាប្រធាន
2. លោក ឈឺន សេងហ៊ន់ នាយករង ជាអនុប្រធាន
3. លោក ម៉ាន់ រ៉ាវុត នាយករង ជាអនុប្រធាន
4. លោក គង់ សេងលី ហេរញ្ញិកសាលា ជាសមាជិក
5. លោក-លោកស្រី ជាប្រធានក្រុមបច្ចេកទេសទាំងអស់ជាសមាជិក
6. លោក ជុំ សាបាន តំណាងសហគមន៍ ជាសមាជិក
7. លោកស្រី វៀន សារ៉េត តំណាងសហគមន៍ ជាសមាជិក

**ប្រការ២៖**មូលនិធិដំណើរការសាលារៀនសាធារណៈ មានគោលបំណងកសាងសមត្ថភាពដឹកនាំ និងគ្រប់គ្រងដល់មន្ត្រី គ្រូបង្រៀន និងអ្នកពាក់ព័ន្ធជាដើម ក្នុងការចូលរួមអភិវឌ្ឍន៍សាលារៀន ស្របនឹងគោលនយោបាយទី២ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ស្តីពីការធានាស័ក្តិសិទ្ធភាព នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីគ្រប់លំដាប់ថ្នាក់ ។ **សមាសភាព(គ.ម.ស)** នីមួយៗមានតួនាទីជាមូលដ្ឋានដូចខាងក្រោម ៖

**ក. ប្រធាន**

- ដឹកនាំចាត់ចែង សម្របសម្រួលរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- ធានាការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងដំណើរការអភិវឌ្ឍន៍សាលារៀន
- ដឹកនាំការកៀរគរថវិកាសម្រាប់អភិវឌ្ឍន៍សាលារៀន
- ពិនិត្យ និងសម្រេចលើគម្រោងទិញសម្ភារៈ ជួសជុល សាងសង់ និងសេវានានា

- ចុះហត្ថលេខាលើមូលប្បទានប័ត្រ
- ពិនិត្យនិងសម្រេចលើប័ណ្ណចំណូល គំរូលេខ)១គ) សំណើសុំថវិកា (ំរូលេខ ២(ប័ណ្ណចំណាយ គំរូលេខ ) (៣
- ពិនិត្យ និងឯកភាពលើបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ (គំរូលេខ ៤)បញ្ជីបេឡា (គំរូលេខ ៥)របាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច .តារាងលេខ ២)១ក.តារាងលេខ ២) តាមសកម្មភាព (១ខ.តារាងលេខ ៣) និងរបាយការណ៍ទូទាត់ចំណាយថវិកា (១(
- ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុជូនការិយាល័យអប់រំយុវជននិងកីឡាក្រុងខណ្ឌ តាម/ស្រុក/ពេលកំណត់
- ***បង្កើត និងរៀបចំ*** ***ក្រូណូទាំង ៣*** ***ដាក់ឯកសារៈ*** *1-ប្រតិបត្តិការបច្ចេកទេស* *2-ប្រតិបត្តិការហិរញ្ញវត្ថុ* *3-របាយការណ៍* ។
- ពិនិត្យតាមដាន និងផ្សព្វផ្សាយលទ្ធផលការងារជូនភាគីពាក់ព័ន្ធ
- ចូលរួមសហការក្នុងពេលដំណើរការអធិការកិច្ច និងសវនកម្ម

**ខ. អនុប្រធាន**

- ជួយការងារប្រធាន
- ចូលរួមកៀរគរថវិកាសម្រាប់អភិវឌ្ឍន៍សាលារៀន
- ចូលរួមក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធ សាស្រ្តថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- ចុះហត្ថលេខាលើមូលប្បទានប័ត្រនៅពេលមានការផ្ទេរសិទ្ធិជូនពីប្រធាន
- ពិនិត្យ និងចុះហត្ថលេខាលើប័ណ្ណចំណូល សំណើសុំចំណាយថវិកា និងប័ណ្ណចំណាយ
- ពិនិត្យ និងចុះហត្ថលេខាលើបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ បញ្ជីបេឡា របាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច តាមសកម្មភាព និងរបាយការណ៍ទូទាត់ចំណាយថវិកា
- រៀបចំរបាយការណ៍បច្ចុប្បន្នភាពព័ត៌មានហិរញ្ញវត្ថុ (គំរូលេខ ៨)និងត្រូវបិទផ្សាយនៅក្នុងបរិវេណសាលារៀន និងបញ្ចូរព័ត៌មានដទៃទៀត
- រៀបចំហឹបតម្លាភាព និងដាក់តម្កល់នៅជាប់ខ្លោងទ្វារសាលារៀន
- តាមដានការអនុវត្តផែនការសកម្មភាពរបស់អ្នកអនុវត្តនីមួយៗ
- ពិនិត្យតាមដានការរៀបចំទុកដាក់ឯកសារឱ្យបានត្រឹមត្រូវ ។

**គ. ហេរញ្ញិក**

ចូលរួមក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្រ្តថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ។

- កត់ត្រាចូលបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ
- ត្រូវរៀបចំមូលប្បទានប័ត្រដកសាច់ប្រាក់ពីធនាគារដើម្បីដាក់ជូនប្រធានពិនិត្យ និង សម្រេច
- បើកសាច់ប្រាក់ពីធនាគារ និងរក្សាសាច់ប្រាក់ទុកក្នុងទូដែកឱ្យមានសុវត្ថិភាព
- រៀបចំប័ណ្ណចំណូល និងប័ណ្ណចំណាយសម្រាប់ដាក់ជូនប្រធានពិនិត្យ និងសម្រេចតាមឋានានុក្រម
- បើកសាច់ប្រាក់ជូនអ្នកស្នើសុំផ្អែកតាមសំណើសុំចំណាយថវិកានិងប័ណ្ណចំណាយដែលបាន ឯកភាពពីប្រធាន
- កត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុចូលក្នុងបញ្ជីបេឡា
- រៀបចំរបាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច តាមសកម្មភាព និងរបាយការណ៍ទូទាត់ចំណាយថវិកា ផ្ញើជូន ការិយាល័យអប់រំ យុវជន និងកីឡាក្រុងខណ្ឌ តាមពេលកំណត់/ស្រុក/
- រៀបចំទុកដាក់កិច្ចបញ្ជិកាគណនេយ្យ និងឯកសារគាំទ្រផ្សេងៗឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាពសម្រាប់ជាកម្មវត្ថុនៃការពិនិត្យតាមដាន អធិការកិច្ច និងសវនកម្ម

– ផ្តល់ការគាំទ្រ និងសហការក្នុងដំណើរការពិនិត្យតាមដាន អធិការកិច្ច និងសវនកម្ម។

**ឃ. សមាជិក**

**១ ប្រធានក្រុមបច្ចេកទេស និងតំណាងគ្រូបង្រៀន .**

- ចូលរួមក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- សម្របសម្រួល និងអញ្ជើញអ្នកពាក់ព័ន្ធ ដូចជា ក្រុមបច្ចេកទេស គ្រូបង្រៀន តំណាងអាជ្ញាធរ សហគមន៍ មាតាបិតាសិស្ស និងសិស្ស ចូលរួមក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- រៀបចំ និងណែនាំគ្រូបង្រៀន ព្រមទាំងអ្នកពាក់ព័ន្ធរៀបចំសំណើសុំចំណាយថវិកា សម្រាប់បម្រើសេចក្តីត្រូវការក្នុងដំណើរការរៀន និងបង្រៀន

- ចុះហត្ថលេខាលើមូលប្បទានប័ត្រ ពេលហេរញ្ញិក ផ្ទេរសិទ្ធិជូន ដោយមានការឯកភាពពីប្រធាន គស.ម.
- ជួយផ្សព្វផ្សាយបន្តអំពីដំណើរការអភិវឌ្ឍន៍ និងសមិទ្ធផលសាលារៀន ដល់សហគមន៍ និង ភាគីពាក់ព័ន្ធ។

**២. តំណាងសហគមន៍**

- សម្របសម្រួល និងចូលរួមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- ចូលរួមកៀរគរថវិកាសម្រាប់អភិវឌ្ឍន៍សាលារៀន
- ជួយផ្សព្វផ្សាយការងារសាលារៀនដល់សហគមន៍
- បើក ហឹបតម្លាភាព នៅមុខអង្គប្រជុំ និងអានជូនអង្គប្រជុំដើម្បីទទួលបានព័ត៌មានត្រឡប់ពីសហគមន៍ដើម្បីដោះស្រាយ
- តាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់សាលារៀន
- តាមដានការបិទផ្សាយជាសាធារណៈលើលទ្ធផលអនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ។

**សមាជិក-សមាជិកា នៃគណៈកម្មការខាងលើត្រូវចូលរួមប្រជុំតាមការអញ្ជើញ របស់ប្រធាន ឬអនុប្រធាន ។**

សម្គាល់ ៖

❖ សិទ្ធិចុះហត្ថលេខា និងសម្រេចលើគណនីធនាគារ មានចំនួន ៤នាក់) គឺ ៖

○ប្រភេទA ៖ ប្រធាន និងអនុប្រធាន (សរុប២នាក់)

○ប្រភេទB ៖ ហេរញ្ញិក និងសមាជិក (សរុប២នាក់)

( *ក្នុងករណីសាលារៀនមិនមានសមាសភាពគ្រប់ត្រូវខ្ចីសមាសភាពពីសាលាកម្រង និងមានការឯកភាពពីគណៈកម្មការគ្រប់គ្រង* )

❖ មូលប្បទានប័ត្រដកសាច់ប្រាក់ពីធនាគារ ត្រូវចុះហត្ថលេខាដោយអ្នកមានសិទ្ធិចំនួន ០២ រូប៖

•ករណីទី១៖ ត្រូវមានហត្ថលេខាប្រភេទA ១រូប(ប្រធាន ឬអនុប្រធាន១រូប) និងប្រភេទB ១រូប(ហេរញ្ញិក ឬសមាជិក១រូប)

•ករណីទី២៖ ត្រូវមានហត្ថលេខា ប្រភេទA ២រូប (ប្រធាន និង អនុប្រធាន) ឬ ប្រភេទ B ២រូប ( ហេរញ្ញិក និង សមាជិក) អនុវត្តតែក្នុងករណីអវត្តមានប្រភេទណាមួយទាំងពីរ ។

បានឃើញ និងឯកភាព

ថ្ងៃ..........................ខែ.................ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

**កន្លែងទទួល ៖**

សំឡូត,ថ្ងៃទី.......................ខែ.....................ឆ្នាំ ២០.......

**ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្ត**

-ការិយាល័យអប់រំ យុវជន និងកីឡាស្រុកសំឡូត ផ្នែក (គ.ន)

" ដើម្បីជូនជ្រាបជាព័ត៌មាន "

-សាមីខ្លួន (ដើម្បីទទួលស្គាល់ និងអនុវត្ត )

-ឯកសារកាលប្បវត្តិ

- ការអភិវឌ្ឍសមត្ថភាពស្ថាប័ន៖ បុគ្គលិកទាំងអស់ត្រូវបានលើកទឹកចិត្តនិងផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពខ្លួនឯងជាប្រចាំ តាមរយៈការស្វែងរកអាហារូបករណ៍ជាមួយដៃគូអភិវឌ្ឍ និងសាកលវិទ្យាល័យនានា ដើម្បីបំប៉នលើជំនាញ ឯកទេសបន្ថែម និងបច្ចេកវិទ្យាព័ត៌មាន ដើម្បីអោយការបង្រៀន និងរៀនមានប្រសិទ្ធភាព និងគុណភាព ប្រកបដោយនវានុវត្តន៍ ស្របតាមបរិបទឧស្សាហកម្ម៤.០។








*រូបភាពទី២ និងទី៣: ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងការបង្រៀន និងរៀន និងការគ្រប់គ្រងរដ្ឋបាល*





*រូបភាពទី៤ និងទី៥: ការការចុះអនុស្សារណៈយោគយល់គ្នារវាងវិទ្យាល័យសំឡូត និងសាកលវិទ្យាល័យជាតិបាត់ដំបង*

- និយ័តភាពការងារ៖ ត្រូវបានពង្រឹងជាប់ជាប្រចាំ តាមរយៈការត្រួតពិនិត្យវត្តមានផ្ទាល់ និងប្រើប្រព័ន្ធតាមដានតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យសាលាផ្ទាល់ និងប្រព័ន្ធគ្រប់គ្រងវត្តមានបុគ្គលិកអប់រំរបស់មន្ទីរអប់រំយុវជននិងកីឡាខេត្តបាត់ដំបងរៀងរាល់ថ្ងៃ។




*រូបភាពទី៦: ប្រព័ន្ធគ្រប់គ្រងវត្តមានបុគ្គលិកអប់រំប្រចាំថ្ងៃរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តបាត់ដំបង*

- ការរៀបចំគណៈកម្មការផ្សេងៗនិងដំណើរការ៖ គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន ថ្នាក់រៀន និងគណៈកម្មការផ្សេងៗបានរៀបចំតាមការណែនាំរបស់ក្រសួងអប់រ
- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស៖ ធ្វើឡើងជាប្រចាំតាមរយៈការប្រឡងតេស្តស្តង់ដាដើមឆ្នាំ តេស្តស្តង់ដាប្រចាំខែ ឆមាស ជាដើម និងធ្វើការប្រៀបធៀបលទ្ធផលការសិក្សាសិស្សជាពិសេសលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ តាមឆ្នាំនីមួយៗផងដែរ។

**២.វិភាគការចូលរៀននៅឆ្នាំសិក្សា ២០១៨-២០១៩ ដល់ ឆ្នាំសិក្សា២០២២-២០២៣**

នៅក្នុងការវិភាគការចូលរៀន វិទ្យាល័យសំឡូត បានលើកយកសូចនាករចំនួន ៥ ដើម្បីមកធ្វើការវិភាគ ដូចជា អត្រាពិតចូលរៀនថ្មី អត្រាពិតនៃការសិក្សានៅបឋមសិក្សា អត្រាបញ្ចប់ការសិក្សា អត្រាឆ្លងភូមិសក្សាពីបឋមសិក្សា ទៅមធ្យមសិក្សាបឋមភូមិ និងអត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ។

*តារាងទី១៖ វឌ្ឍនភាពនៃសូចនាករការចូលរៀន រយៈពេល ៥ ឆ្នាំ*

| សូចនាករ | ឆ្នាំសិក្សា ២០១៨-២០១៩ | | ឆ្នាំសិក្សា ២០១៩-២០២០ | | ឆ្នាំសិក្សា ២០២០-២០២១ | | ឆ្នាំសិក្សា ២០២១-២០២២ | | ឆ្នាំសិក្សា ២០២២-២០២៣ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១.អត្រាពិតចូលរៀនថ្មី | 89.56 | 91.65 | 90.59 | 92.12 | 90.56 | 89.61 | 93.78 | 92 | 96 | 95 |
| ២.អត្រាពិតនៃការសិក្សា | 89.25 | 85.46 | 91.25 | 89 | 92 | 89.79 | 92.58 | 90.46 | 96 | 95 |
| ៣.អត្រាបញ្ចប់ការសិក្សា | 86.89 | 79.67 | 89 | 82.67 | 90 | 89 | 89.89 | 88.67 | 97 | 95 |
| ៤.អត្រាឆ្លងភូមិសិក្សាចូលម.បឋមភូមិ | 90 | 87 | 91 | 88 | 92 | 90 | 92 | 89 | 97 | 95 |
| ៥.អត្រាឆ្លងភូមិសិក្សាចូលម.ទុតិយភូមិ | 89.67 | 88 | 90.62 | 89 | 91 | 90 | 93 | 91 | 97 | 95 |

**៣.វិភាគគុណភាពសិក្សានៅឆ្នាំសិក្សា ២០១៨-២០១៩ ដល់ ឆ្នាំសិក្សា២០២២-២០២៣**

នៅក្នុងការវិភាគគុណភាពសិក្សា វិទ្យាល័យសំឡូត បានលើកយកសូចនាករចំនួន ០៧ ដើម្បីមកធ្វើការវិភាគ ដូចជា អត្រាឡើងថ្នាក់ អត្រាត្រួតថ្នាក់ អត្រាបោះបង់ការសិក្សា ផលធៀបសិស្ស/ថ្នាក់ ផលធៀបសិស្ស/គ្រូ ភាគរយសិស្សប្រឡងជាប់មធ្យមសិក្សាបឋមភូមិ និងភាគរយសិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ។

*តារាងទី២៖ វឌ្ឍនភាពនៃសូចនាករគុណភាពសិក្សា រយៈពេល ០៥ ឆ្នាំ*

| សូចនាករ | ឆ្នាំសិក្សា ២០១៨-២០១៩ | | ឆ្នាំសិក្សា ២០១៩-២០២០ | | ឆ្នាំសិក្សា ២០២០-២០២១ | | ឆ្នាំសិក្សា ២០២១-២០២២ | | ឆ្នាំសិក្សា ២០២២-២០២៣ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១.អត្រាឡើងថ្នាក់ | 89 | 87 | 90.45 | 89 | 89.65 | 88 | 91 | 90 | 96 | 95 |
| ២.អត្រាត្រួតថ្នាក់ | 4 | 5 | 4 | 2 | 3 | 4 | 2 | 3 | 1 | 1 |
| ៣.អត្រាបោះបង់ការសិក្សា | 7 | 8 | 6 | 9 | 8 | 8 | 7 | 7 | 3 | 4 |
| ៤.ផលធៀបសិស្ស/ថ្នាក់ | 63 | 32 | 66 | 37 | 37 | 18 | 38 | 18 | 47 | 25 |
| ៥.ផលធៀបសិស្ស/គ្រូ | 21 | 12 | 23 | 13 | 25 | 11 | 26 | 12 | 28 | 12 |
| ៦.ភាគរយសិស្សប្រឡងជាប់មធ្យមសិក្សាបឋមភូមិ | 86 | 90 | 100 | 100 | 97 | 100 | 95 | 98 | 98 | 100 |
| ៧.ភាគរយសិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ | 53 | 56 | 99 | 100 | 27 | 17 | 96 | 98 | 97 | 100 |

## ខ.បញ្ហាប្រឈម

- អត្រាពិតចូលរៀនថ្មីនៅមានកម្រិតទាបនៅឡើយ
- អត្រាពិតនៃការសិក្សាមានកម្រិតទាបនៅឡើយ
- អត្រាបញ្ចប់ការសិក្សាមានកម្រិតទាបនៅឡើយ
- អត្រាឡើងថ្នាក់នៅមានកម្រិតទាបនៅឡើយ
- អត្រាត្រួតថ្នាក់នៃការសិក្សានៅមានកម្រិតខ្ពស់នៅឡើយ
- អត្រាបោះបង់ការសិក្សានៅតែមានកម្រិតខ្ពស់នៅឡើយ
- បញ្ហាបរិស្ថានសាលារៀនមិនទាន់បានប្រសើរនៅឡើយ
- គ្រូបង្រៀនមួយចំនួនតូចពុំទាន់អាចបង្រៀនតាមបែបទំនើប ឬតាមប្រព័ន្ធព័ត៌មានវិទ្យានៅឡើយ
- ការអនុវត្តម៉ោងសិក្សាពុំបានពេញលេញនៅឡើយ ដោយសារខ្វះអគារសិក្សា និងបន្ទប់មពិសោធន៍
- ភាគរយសិស្សប្រឡងជាប់មធ្យមភាគនៅកម្រិតទាប
- ការអនុវត្តតេស្តបញ្ចប់មេរៀន ប្រចាំខែ និងប្រចាំឆមាសមិនទាន់ធ្វើបានល្អនៅឡើយ

- គ្រូកែកិច្ចការផ្ទះសិស្សមិនបានជាប្រចាំ និងមិនបានអនុវត្តកិច្ចការផ្ទះជាគម្រោង
- ការជួយសិស្សមករៀនមិនទាន់ពេលនិងសិស្សរៀនយឺតមិនបានសម្រេចតាមផែនការ ។
- ការជួយគាំទ្រសិស្សពិការ និងសិស្សក្រីក្រមិនទាន់គ្រប់តម្រូវការសិក្សា
- សម្ភារៈបង្រៀននិងរៀនមិនទាន់បានផ្ដល់ឱ្យសមស្របតាមគោលបំណងមេរៀន
- ខ្វះសម្ភារឧបទេស សម្ភារពិសោធន៍
- គណៈកម្មការគ្រប់គ្រងសាលារៀន មួយចំនួនតូចមិនសូវបានចូលរួមប្រជុំទៀងទាត់
- ខ្វះគ្រូឯកទេស
- ខ្វះអគារសិក្សា
- ខ្វះបង្គន់អនាម័យស្តង់ដា

## ៦.គោលបំណង

- ប្រែក្លាយបរិស្ថានសាលាឱ្យក្លាយជាសាលាបៃតងមានបរិស្ថាជាទីមេត្រីរបស់គ្រប់អ្នកសិក្សាទិសដៅប្រមូលកុមារដល់និងក្នុងវ័យសិក្សាឱ្យចូលរៀនបានច្រើន និងបន្តឱ្យពួកគេរៀនឱ្យបានចប់គ្រប់ៗគ្នា រៀនប្រកបដោយចំណេះដឹងដែលអាចបន្តការសិក្សានៅកម្រិតឧត្តមសិក្សា ប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់ ។
- ជំរុញការអនុវត្តនូវវិធីសាស្ត្របង្រៀនថ្មីៗ តាមបែបរិះរក ពិសេសលើមុខវិជ្ជាវិទ្យាសាស្ត្រ គណិតវិទ្យា បច្ចេកវិទ្យា តាមរយៈការសង្កេត ស្រាវជ្រាវវត្ថុជាក់ស្ដែង ទីពិសោធន៍ ការប្រើប្រាស់ប្រព័ន្ធ IT ។ល។ ជំរុញគ្រូឱ្យធ្វើកិច្ចតែងការបង្រៀនមុននឹងបង្រៀនសិស្សលើគ្រប់មុខវិជ្ជា គ្រប់ម៉ោងបង្រៀន ត្រូវបង្រៀនឱ្យបានចប់ និងឱ្យមានគុណភាពតាមកម្មវិធីសិក្សាដែលក្រសួងបានកំណត់ និងត្រូវអនុវត្តធ្វើតេស្ត គ្រប់ប្រភេទ ឱ្យមានប្រសិទ្ធភាព យុត្តិធម៌ តម្លាភាព ។
- លើកកម្ពស់ការចូលរៀនរហូតដល់ចប់ថ្នាក់ទី៦ សម្រាប់កុមារទាំងអស់ ជាពិសេសកុមារជួបការលំបាក
- កែលម្អការផ្ដល់សេវាអប់រំប្រកបដោយគុណភាព
- ពង្រឹងអភិបាលកិច្ចល្អ ក្នុងការដឹកនាំ និងគ្រប់គ្រងប្រកបដោយគុណភាពខ្ពស់ ក្នុងក្របខណ្ឌយុទ្ធសាស្ត្រសហគមន៍សាលារៀន

## ៧.ចំណុចដៅរបស់សាលារៀន

- អត្រាពិតចូលរៀនថ្មីកើនឡើងពី.....% នៅឆ្នាំសិក្សា ២០១៨-២០១៩ ទៅ .........% នៅឆ្នាំសិក្សា ២០២២-២០២៣
- អត្រាពិតចូលរៀនថ្មី(ស្រី)កើនឡើងពី.....% នៅឆ្នាំសិក្សា ២០១៨-២០១៩ ទៅ .........% នៅឆ្នាំសិក្សា ២០២២-២០២៣
- អត្រាពិតនៃការសិក្សាកើនឡើងពី.....% នៅឆ្នាំសិក្សា ២០១៨-២០១៩ ទៅ .........% នៅឆ្នាំសិក្សា ២០២២-២០២៣
- អត្រាពិតនៃការសិក្សា(ស្រី)កើនឡើងពី.....% នៅឆ្នាំសិក្សា ២០១៨-២០១៩ ទៅ .........% នៅឆ្នាំសិក្សា ២០២២-២០២៣
- អត្រាបោះបង់ការសិក្សាថយពី.....% នៅឆ្នាំសិក្សា ២០១៨-២០១៩ មកនៅត្រឹម .........% នៅឆ្នាំសិក្សា ២០២២-២០២៣
- អត្រាបោះបង់ការសិក្សា(ស្រី)ថយពី.....% នៅឆ្នាំសិក្សា ២០១៨-២០១៩ មកនៅត្រឹម .........% នៅឆ្នាំសិក្សា ២០២២-២០២៣
- អត្រាត្រួតថ្នាក់ថយពី.....% នៅឆ្នាំសិក្សា ២០១៨-២០១៩ មកនៅត្រឹម .........% នៅឆ្នាំសិក្សា ២០២២-២០២៣
- អត្រាត្រួតថ្នាក់(ស្រី)ថយពី.....% នៅឆ្នាំសិក្សា ២០១៨-២០១៩ មកនៅត្រឹម .........% នៅឆ្នាំសិក្សា ២០២២-២០២៣
- អត្រាបញ្ចប់ការសិក្សាកើនឡើងពី.....% នៅឆ្នាំសិក្សា ២០១៨-២០១៩ ទៅ .........% នៅឆ្នាំសិក្សា ២០២២-២០២៣
- អត្រាបញ្ចប់ការសិក្សា(ស្រី)កើនឡើងពី.....% នៅឆ្នាំសិក្សា ២០១៨-២០១៩ ទៅ .........% នៅឆ្នាំសិក្សា ២០២២-២០២៣
- អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិកើនឡើងពី.....% នៅឆ្នាំសិក្សា ២០១៨-២០១៩ ទៅ .........% នៅឆ្នាំសិក្សា ២០២២-២០២៣

- អត្រាសិស្សប្រឡងជាប់មធ្យមសិក្សាបឋមភូមិ(ស្រី)កើនឡើងពី៨៦% នៅឆ្នាំសិក្សា ២០១៨-២០១៩ ទៅ ៩៨% នៅឆ្នាំសិក្សា ២០២២-២០២៣
- អត្រាសិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិកើនឡើងពី៥៣% នៅឆ្នាំសិក្សា ២០១៨-២០១៩ ទៅ ៩៧% នៅឆ្នាំសិក្សា ២០២២-២០២៣
- ចំនួនថ្នាក់រៀនបានរៀបចំឱ្យស្របតាមការអនុវត្តកម្មវិធីសាលាកុមារមេត្រីកម្រិតអភិវឌ្ឍ
- សាលារៀនមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់
- ការអនុវត្តស្តង់ដាទឹកស្អាត និង អនាម័យ
  - ការរៀបចំឱ្យមានបង្គន់អនាម័យឱ្យស្របតាមនិយាម និងមានស្តង់ដា
  - ទឹកស្អាតរៀបចំឱ្យមានបណ្តាញទឹកស្អាត
  - រៀបចំឱ្យមានកន្លែងលាងសំអាតដៃ
  - រៀបចំឱ្យមានបន្ទប់សុខភាពសិក្សា និងប្រអប់សង្គ្រោះបឋមគ្រប់បន្ទប់រៀន
- ចំនួនសិស្សបានទទួលអាហារប្រកបដោយអនាម័យខ្ពស់ និងគុណភាពល្អ
- ចំនួនសិស្សបានទទួលអាហារូបករណ៍ឆ្លើយតបនឹងតម្រូវការជាក់ស្តែង
- ភាគរយសិស្សមានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងប្រព័ន្ធព័ត៌មានវិទ្យាច្រើន

## ៨.យុទ្ធសាស្ត្រ និងសកម្មភាព

- **ពង្រឹងការប្រមូលកុមារចូលរៀន និងរក្សាឱ្យគង់វង្សនៅមធ្យមសិក្សាប្រកបដោយសមធម៌**
  - ប្រមូលកុមារដល់និងក្នុងវ័យសិក្សាឱ្យចូលរៀនពិសេសកុមារពិការ កុមារលំបាក តាមរយៈការប្រជុំជាមួយសហគមន៍ អង្វាធរមូលដ្ឋាន
  - រៀបចំផែនទីសិក្សា ផែនទីខ្នងផ្ទះ និងស្ថិតិសិស្ស តាមរយៈការចុះសួរដល់ផ្ទះ
  - ផ្សព្វផ្សាយ និងយុទ្ធនាការប្រមូលកុមារចូលរៀន
  - ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ
  - ផ្តល់ការគាំទ្រដល់គ្រួសារដែលត្រូវការពិភាក្សាជាមួយដើម្បីបញ្ជូនកូនមករៀន
  - កែលម្អបរិស្ថាន និងទីធ្លាកំសាន្តអោយមានភាពទាក់ទាញ
  - ពិនិត្យចំនួនសិស្សចុះឈ្មោះចូលរៀន
  - ចុះសួរសុខទុក្ខដល់ផ្ទះសិស្ស
  - **ពង្រឹងគុណភាពបង្រៀន និងរៀន**
  - សាលារៀនធ្វើតេស្តស្តង់ដាសិស្សថ្នាក់ទី៦ចុងឆ្នាំ ក្នុងសាលាបឋមសិក្សាចំណុះ
  - ផលិត សម្ភារៈឧបទ្ទេសសម្រាប់រៀន និងអនុវត្តវិធីសាស្ត្របង្រៀនសមស្រប
  - ផលិត  សម្ភារៈពិសោធន៍ និងការពិសោធន៍
  - បង្កើនម៉ោងសិក្សាសម្រាប់កម្មវិធីបំណិនជីវិតរកចំណូល (កសិកម្ម  រោងជាង ព័ត៌មានវិទ្យា និងវិនិយោគ)
  - ផលិត សម្ភារៈបណ្ណាល័យ សៀវភៅ និងឯកសារអំណាន និងកែលម្អបណ្ណាល័យឱ្យស្របតាមស្តង់ដាសតវត្សទី២១ គ្រប់គ្រងដោយប្រព័ន្ធបច្ចេកវិទ្យា
  - ប្រធានក្រុមបច្ចេកទេស រួមជាមួយសិស្ស និងគ្រូបង្រៀន រៀបចំបន្ទប់ សម្រាប់បង្រៀន ដោយបំពាក់សម្ភារឧបទ្ទេស ឱ្យមានសោភ័ណភាព សណ្តាប់ធ្នាប់ និងអនាម័យ
  - រៀបចំប្រព័ន្ធគ្រប់គ្រងសៀវភៅសិក្សាគោលដើម្បីធានាឱ្យសិស្សមានសៀវភៅប្រើប្រាស់គ្រប់គ្រាន់
  - ជួយសិស្សរៀនយឺតជាប្រចាំ រៀបចំវិធីសាស្ត្របង្រៀន និងប្រព័ន្ធវាយតម្លៃ
  - រៀបចំបន្ទប់ឧបករណ៍បច្ចេកវិទ្យាដូចជាម៉ាស៊ីនបញ្ចាំង LCD កុំព្យូទ័រ និងសម្ភារៈបង្រៀនផ្សេងៗទៀត

- ប្រជុំបច្ចេកទេសតាមមុខវិជ្ជា
- រៀបចំតេស្តល្បឿនអំណានភាសាខ្មែរ តេស្តគណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គមឱ្យមានគុណភាពនិងប្រសិទ្ធភាពទាំងលើប្រធានវិញ្ញាសា ដំណើរការសំណេរ និងការដាក់ពិន្ទុវាយតម្លៃ
- បែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា
- អធិការកិច្ចលើគ្រូបង្រៀនតាមថ្នាក់
- ប្រជុំរវាងគ្រូបង្រៀន មាតាបិតា និង សិស្សរៀនយឺត (សិស្សត្រួតថ្នាក់ពីឆ្នាំមុន សិស្សដែលមាន ពិន្ទុទាបជាង៦០%ពីចុងឆ្នាំសិក្សាមុន នៅបំណាច់ខែ និងនៅចុងឆ្នាំសិក្សា
- ជំរុញសិស្សឱ្យមករៀនបានទៀងទាត់
- ពង្រឹងបទបញ្ជាផ្ទៃក្នុង
- ពង្រឹងវិន័យរបស់សិស្ស
- លើកទឹកចិត្តសិស្សធ្វើម
- អនុវត្តសកម្មភាពសំណួរ និងចម្លើយ ដើម្បីជួយសិស្សឱ្យឆ្លុះបញ្ចាំងពីបទពិសោធន៍ថ្មីៗ ដើម្បីកសាងនូវគំនិតថ្មីមួយដែលអាចដោះស្រាយបញ្ហាជីវិតជាក់ស្តែង
- ផ្តោតលើការបង្រៀនជំនាញការគិតនៅកំពូលទ្រឹស្តី Bloom រួមមានការវិភាគ ការសំយោគ និងការ វាយតម្លៃ រំញោចសិស្សឱ្យផ្លាស់ប្តូរគំនិត តាមរយៈការពិភាក្សា លើកទឹកចិត្តសិស្សឱ្យចេះសំយោគ គំនិតតែមួយគត់
- សរសេរកិច្ចតែងការបង្រៀនមុនមកបង្រៀនឱ្យបានគ្រប់មេរៀន រាល់ម៉ោងបង្រៀន និង ត្រូវអនុវត្តវិធីសាស្ត្របង្រៀនបែបសិក្សាគម្រោង និង បំផុសគំនិត
- បង្រៀនឱ្យបានចប់តាមកម្មវិធីសិក្សាដែលក្រសួងណែនាំ និង ឱ្យមានគុណភាព
- ប្រើប្រាស់សៀវភៅសិក្សាគោលឱ្យមានប្រសិទ្ធភាពក្នុងពេលបង្រៀននិងរៀន
- ប្រជុំទៀងទាត់ដល់គ្រូបង្រៀនតាមមុខវិជ្ជា ដើម្បីធ្វើថ្នាក់និទស្សន៍ ដោយផ្តោតលើវិធីសាស្ត្របង្រៀន
- ផ្សព្វផ្សាយលទ្ធផលសិក្សាប្រចាំខែ ឆមាស និងប្រចាំឆ្នាំ ជាសាធារណៈ
- **ពង្រឹងការគ្រប់គ្រង និងដឹកនាំសាលារៀនប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់**
- ធ្វើស្វ័យវាយតម្លៃគ្រូបង្រៀន អំពីកម្រិតចំណេះដឹងខ្លឹមសារមុខវិជ្ជា និងសមត្ថភាពប្រតិបត្តិវិជ្ជាជីវៈរៀងរាល់៣ខែម្តង ដើម្បីឱ្យបានដឹងពីកម្រិតសមត្ថភាព និងបទពិសោធន៍លើការងារបង្រៀន និងរៀន
- ធ្វើរបាយការណ៍សមិទ្ធកម្មតាមត្រីមាស ឆមាស ដំណាច់ឆ្នាំ
- បង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន និងលើកទឹកចិត្តសហគមន៍ឱ្យចូលរួម ក្នុងការគ្រប់គ្រងសាលារៀន
- រៀបចំនិងអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយមានការចូលរួមពីគ្រប់ ភាគីពាក់ព័ន្ធទាំងអស់រួមទាំងក្រុមប្រឹក្សាកុមារ យុវជន
- ពិនិត្យឡើងវិញការបំពេញការងាររបស់សាលារៀន និងតម្លាភាព
- រៀបចំ រដ្ឋបាលសាលារៀន
- រៀបចំផែនការថវិកាប្រចាំឆ្នាំ
- រៀបចំផែនការអធិការកិច្ចគ្រូបង្រៀន
- ប្រជុំ វាយតម្លៃលទ្ធផលប្រចាំឆ្នាំ លើការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន (របាយការណ៍ប្រចាំឆ្នាំ)
- រៀបចំកិច្ចប្រជុំទៀងទាត់ជាមួយមាតាបិតាសិស្ស និងចុះតាមខ្នងផ្ទះ
- ប្រជុំជាទៀងទាត់ជាមួយមាតាបិតាសិស្សនិងសហគមន៍មូលដ្ឋាន ដើម្បីកិច្ចសហការគាំទ្រ
- ណែនាំគ្រូចេញថ្មី និងគ្រូកិច្ចសន្យា
- ទប់ស្កាត់បាតុភាពមិនប្រក្រតីក្នុងសាលារៀន

- ○ បែងចែកសៀវភៅសិក្សាគោលតាមនិយាម
- ○ ចាត់ចែង និងប្រើប្រាស់ថវិកាប្រចាំឆ្នាំ
- ○ បង្កើតបណ្ណាល័យតាមស្តង់ដា
- ○ **អនុវត្តការគ្រប់គ្រងតាមសាលារៀន**
- ○ សម្របសម្រួលជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ អភិវឌ្ឍសាលារៀនរយៈពេល ៥ឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយកំណត់សូចនាករជាតុចូល ជាតុចេញ និងផលសម្រេច ព្រមទាំងប្រភពហិរញ្ញប្បទាន ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់
- ○ ប្រមូលព័ត៌មានជាក់ស្តែង ពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការវាយតម្លៃសមត្ថភាពរបស់គ្រូបង្រៀន និងការវាយតម្លៃការអនុវត្តរបស់សាលារៀន
- ○ អនុវត្តប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងស្នើរង្វាន់ដល់បុគ្គលិកដែលបំពេញការងារបានល្អ ព្រមទាំងស្នើវិធានការរដ្ឋបាលសម្រាប់បុគ្គលិកអសកម្មការងារ
- ○ ផ្សព្វផ្សាយទិន្នន័យនិងព័ត៌មានរបស់សាលារៀនដល់សហគមន៍ អាជ្ញាធរមូលដ្ឋាន
- **គណៈកម្មការគ្រប់គ្រងសាលារៀន**
- ○ អនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ និងរបាយការណ៍វឌ្ឍនភាព
- ○ លើកទឹកចិត្តឱ្យសហគមន៍ចូលរួមក្នុងការគ្រប់គ្រងសាលារៀន និងធានាការពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងគោលនយោបាយអប់រំដើម្បី៖
  - ▪ ពង្រីកសេវាអប់រំឱ្យបានដល់ក្រុមកុមារងាយរងគ្រោះ និងកុមារពិការ
  - ▪ កែលម្អគុណភាពសេវាអប់រំ
  - ▪ បង្កើនអត្រាចូលរៀននិងអត្រាបញ្ចប់ការសិក្សានៅគ្រប់កម្រិត
  - ▪ កាត់បន្ថយអត្រាបោះបង់ និងអត្រាត្រួតថ្នាក់
- **គ្រប់គ្រងហិរញ្ញវត្ថុ**
- ○ គណៈកម្មការគ្រប់គ្រងសាលារៀនត្រូវបង្កើតឡើង ដើម្បីអនុម័តបទបញ្ញាដែលទាក់ទងទៅនឹងតួនាទីនិងការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងសាលារៀន មាតាបិតាសិស្សនិងសហគមន៍ក្នុងការគ្រប់គ្រងសាលារៀន
- ○ អនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ផែនការប្រតិបត្តិប្រចាំឆ្នាំ និងដាក់សំណើមូលនិធិកែលម្អសាលារៀន ដើម្បីឆ្លងទៅការិ.ស្រុក និងទទួលខុសត្រូវលើការពិនិត្យមើល ការអនុវត្តមូលនិធិកែលម្អសាលារៀន ដែលប្រតិបត្តិដោយសាលា
- ○ ប្រជុំពិភាក្សាជាមួយគ្រូបង្រៀន មាតាបិតាសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋាន អំពីការកសាងនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀននិងផែនការប្រតិបត្តិប្រចាំឆ្នាំ និងលើកវិធានការ ដើម្បីកែលម្អការបំពេញការងាររបស់សាលារៀនឱ្យកាន់តែប្រសើរឡើង។
- ○ **ធ្វើសវនកម្មថវិកាអប់រំជាទៀងទាត់**
- ○ បង្កើតប្រអប់សំបុត្រតម្លាភាព ដើម្បីទទួលបានព័ត៌មានឬពាក្យបណ្តឹងពីអ្នកពាក់ព័ន្ធនាយកសាលាប្រើប្រាស់មូលនិធិកែលម្អសាលារៀន ដើម្បីការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំជាប្រចាំនិងកែលម្អវិធីសាស្ត្របង្រៀន ដែលត្រូវរៀបចំឡើង ដើម្បីលើកកម្ពស់ការគោរពជាតិសាសន៍ និងតម្លៃមនុស្ស

  **គណៈកម្មការគ្រប់គ្រងសាលារៀន**

- ○ ផ្តល់របាយការណ៍ជាប្រចាំ ស្តីពី ភាពពេញចិត្តនៃការគ្រប់គ្រង និងសំណូមពរ
- ○ ផ្សព្វផ្សាយរបាយការណ៍ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុដល់អ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីធានាបាននូវតម្លាភាព។

**គ្រូបង្រៀន**

- ផ្តល់យោបល់កែលម្អដល់នាយកសាលាលើការគ្រប់គ្រងសាលារៀន និងធានាថាមូលនិធិកែលម្អសាលារៀនត្រូវបានប្រើសម្រាប់ដំណើរការបង្រៀននិងរៀន សំដៅបង្កើនលទ្ធផលសិក្សារបស់សិស្ស

**បែងចែកថវិកាផ្សារភ្ជាប់នឹងគោលនយោបាយអប់រំ**

- ពង្រឹងនិយ័តភាពរបស់គ្រូបង្រៀន
- ខិតខំអប់រំសិស្ស ឱ្យគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាលារៀន និងកាលវិភាគសិក្សា ការគោរពច្បាប់ និងសណ្តាប់ធ្នាប់សង្គម ដែលជាជំនាញគ្រប់គ្រងផ្ទាល់ខ្លួន និងលើកទឹកចិត្តសិស្សឱ្យរក្សាអនាម័យនិងធ្វើឱ្យសាលារៀនស្អាត
- ជំរុញការអនុវត្តច្បាប់ស្តីពីការអប់រំ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងកំណត់លក្ខខណ្ឌសម្រាប់ការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន
- ណែនាំពីការធ្វើផែនការថវិកាដោយកំណត់តម្រូវការថវិកា ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនតាមពេលវេលាជាក់លាក់
- គណៈកម្មការគ្រប់គ្រងសាលារៀនរៀបចំរបាយការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនដោយពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តសកម្មភាពជាក់ស្តែង
- ប្រើប្រាស់មូលនិធិកែលម្អសាលារៀនសម្រាប់គាំទ្រសកម្មភាពដូចជា
  - បង្កើនការប្រើប្រាស់សម្ភារបរិក្ខារនិងបរិយាកាសរៀនសូត្រ ដើម្បីគាំទ្រដំណើរការបង្រៀន និងសកម្មភាពរៀនរបស់សិស្ស
  - ពង្រឹងសមត្ថភាពរបស់គ្រូបង្រៀនតាមរយៈការប្រជុំបច្ចេកទេស និងធ្វើថ្នាក់និទស្សន៍
  - ជួយកុមារងាយរងគ្រោះ សិស្សរៀនយឺត និងសិស្សមុខសញ្ញាបោះបង់
  - បង្កើនអត្រាចូលរៀន អត្រាឆ្លងភូមិសិក្សា និងអត្រាបញ្ចប់ការសិក្សា
  - ផ្តល់សេវាថែទាំសុខភាពដល់សិស្សគ្រប់កម្រិតទាំងអស់ (ថែទាំសុខភាព សុវត្ថិភាពចំណីអាហារ និងហានិភ័យផ្សេងៗ )

- ពង្រឹងទំនាក់ទំនងជាមួយសហគមន៍
  - ប្រជុំជ្រើសរើសគណៈកម្មការគ្រប់គ្រង សាលារៀន
  - ប្រជុំប្រឹក្សាយោបល់រវាងគ្រូបង្រៀន មាតាបិតា និងសិស្ស (នៅដើមឆ្នាំសិក្សា និងតាមត្រីមាស)
  - ប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀនតាមការណែនាំ (ពេលបើកបវេសនកាល ចុងឆមាសទី១ ទី២)
  - ប្រជុំជាមួយអាជ្ញាធរមូលដ្ឋានលើកិច្ចការសាលារៀន និងសហការស្រង់ស្ថិតិកុមារដែលមានបញ្ហា
  - នាយកសាលាផ្តួចផ្តើមបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន និងលើកទឹកចិត្តសហគមន៍ឱ្យចូលរួម ក្នុងការគ្រប់គ្រងសាលារៀន
  - នាយកសាលារៀបចំបរិយាកាសការងារនៅក្នុងប្រព័ន្ធគ្រប់គ្រងសាលារៀន ដើម្បីបង្កើនភាពជឿទុកចិត្ត និងការសហការ
  - សាលារៀនគ្រោងថវិកាសម្រាប់គាំទ្រជំនួយរវាងមាតាបិតាសិស្ស និងសហគមន៍មូលដ្ឋានជាមួយ គ្រូបង្រៀន និងគាំទ្រសកម្មភាពប្រជុំក្រុមប្រឹក្សាកុមារ យុវជន។
- **ពង្រឹងគណៈកម្មការគ្រប់គ្រងសាលារៀន**
  - រៀបចំនិងអនុម័តផែនការអភិវឌ្ឍសាលារៀន និងផែនការអភិវឌ្ឍថ្នាក់រៀនដោយមានការចូលរួមពីគ្រប់ ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងក្រុមប្រឹក្សាកុមារ យុវជន
  - ប្រមូលផ្តុំធនធានបន្ថែមសម្រាប់ការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀននិងផែនការអភិវឌ្ឍថ្នាក់រៀន
  - ពិនិត្យឡើងវិញការបំពេញការងាររបស់សាលារៀន និងតម្លាភាព
  - រៀបចំកិច្ចប្រជុំទៀងទាត់ជាមួយមាតាបិតាសិស្ស និងចុះតាមខ្នងផ្ទះ។
  - **គ្រូបង្រៀន**ចូលរួមកិច្ចប្រជុំជាទៀងទាត់ជាមួយមាតាបិតាសិស្សនិងសហគមន៍មូលដ្ឋាន ដើម្បីកិច្ចសហការគាំទ្រ។
  - រៀបចំកិច្ចប្រជុំជាទៀងទាត់ **សិស្ស**ជាមួយអ្នកពាក់ព័ន្ធ និងបង្ហាញទស្សនៈចំពោះ គណៈកម្មការគ្រប់គ្រងសាលារៀន លើវិធី កែលម្អការផ្តល់សេវាអប់រំដល់សិស្ស។

- ពង្រឹងការលើកកម្ពស់ការយល់ដឹង និងបញ្ជ្រាបការងារយេនឌ័រនៅតាមសាលារៀន
  - រៀបចំក្រុមប្រឹក្សាកុមារី
  - ប្រជុំក្រុមប្រឹក្សាកុមារីប្រចាំខែ
  - ប្រជុំ គណៈកម្មការក្រុមប្រឹក្សាសាលារៀន
  - ស្រង់ស្ថិតិកុមារីដែលមានបញ្ហា
  - លើកទឹកចិត្តកុមារីដែលមានបញ្ហា (សម្ភារៈសម្រាប់កុមារីប្រើប្រាស់)
  - រៀបចំសិស្សអង្គុយឆ្លាស់គ្នាក្នុងថ្នាក់រៀន
- បង្កើនការលើកទឹកចិត្ត និងជួយសិស្សតាមតម្រូវការជាក់ស្តែងរបស់គេ ក្នុងការសិក្សានៅសាលារៀន សិស្សខ្សោយគំហើញនិងស្តាប់(មានវ៉ែនតា ឬឧបករណ៍ជំនួយស្តាប់ សិស្សអវត្តមានថយចុះ)
  - បុគ្គលិកគ្រូបង្គោលសុខភាពសិក្សា របស់សាលារៀន រួមជាមួយមណ្ឌលសុខភាព ពិនិត្យភាពខ្សោយគំហើញ និងខ្សោយស្តាប់ និងពិភាក្សាជាមួយមាតាបិតាដើម្បីយកកូនទៅពេទ្យ ឬសេវាជួយនៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ឬកន្លែងផ្តល់សេវាសុខភាពសិស្សផ្សេងទៀត ដែលអាចធ្វើទៅបាន
  - សិស្សប្រើបណ្ណាល័យ (ពិនិត្យតាមដានរាល់ត្រីមាស)
  - សិស្សប្រើបន្ទប់ពិសោធន៍
  - សិស្សប្រើកុំព្យូទ័រ
  - ក្លឹបសិក្សាសិស្ស
  - ជួយសិស្សខ្សោយគំហើញ និងខ្សោយស្តាប់បានទទួលការគាំទ្រដើម្បីរៀនបានប្រសើរ
  - ផ្តល់អាហារូបករណ៍ដល់សិស្ស ក្រុមសិស្សបោះបង់
  - ធ្វើទស្សនកិច្ចសិក្សា
- បង្កើនការលើកកម្ពស់ការអប់រំសុខភាព និងការការពារកុមារ យុវជន ប្រកបដោយសុវត្ថិភាព
  - អប់រំសុខភាព អនាម័យ អប់រំកាយ កីឡា សិល្បះ និងរង្វាន់
  - ជួយកុមារងាយរងគ្រោះ
  - អនុវត្តកម្មវិធីលើកកម្ពស់សុខភាពសិក្សា
- បង្កើនការសាងសង់បន្ទប់រៀន បង្គន់អនាម័យ ផ្ទះសំណាក់គ្រូតាមត្រូវការ
  - បង្កើតក្រុមការងារគាំទ្រការ សាងសង់
  - គណៈគ្រប់គ្រងសាលាបែងចែកបរិវេណក្នុងសាលារៀន ឱ្យគ្រូបង្រៀន និងសិស្សតាមថ្នាក់ ទទួលខុសត្រូវថែរក្សា និងដាំដើមឈើបន្ថែម រក្សាសណ្តាប់ធ្នាប់ និងអនាម័យ។
  - រៀបចំបង្គន់ឱ្យមានសម្រាប់ប្រុស និងស្រី ទ្វារអាចបើកបិទបាននិងមានគន្លឹះ មានទឹក មានសាប៊ូ មានផ្តិល មានអនាម័យ មានដាំផ្កា និងដើមឈើលម្អ។
- បង្កើនការកសាងហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀនប្រកបដោយផាសុកភាព ក្នុងការសិក្សារៀនសូត្រ
  - ថែទាំ និងជួសជុលអគារ បន្ទប់រៀនបន្ថែម
  - រៀបចំផែនទីមេអភិវឌ្ឍបរិស្ថានសាលារៀន ដោយមានការចូលរួមយោបល់ពីគ្រូបង្រៀន សហគមន៍ ក្រុមប្រឹក្សាយុវជន និងកុមារ និងអាជ្ញាធរដែនដី។
  - កែលម្អបរិស្ថានសាលារៀនជាសាលារៀនបៃតង
  - ចាក់ដីបំពេញទីធ្លាសាលា
- បង្កើនការកៀរគរហិរញ្ញប្បទាន និងគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព

- ○ ផ្សព្វផ្សាយខ្លឹមសារផែនការកែលម្អសាលារៀន ដល់សិស្ស គ្រូបង្រៀន មាតាបិតា និងសហគមន៍ តាមរយៈ ការប្រជុំនៅសាលារៀន នៅសហគមន៍ និងក្នុងពិធីបុណ្យនៅវត្ត

○បិទតាំងផែនការកែលម្អសាលារៀននិងថវិកានៅតាមថ្នាក់រៀន សាលារៀន ផ្ទះមេភូមិ សាលាឃុំ មណ្ឌលសុខភាព វត្ត និងទីកន្លែងផ្សេងទៀត។

○កៀរគរធនធានបន្ថែម

○គ្រប់គ្រង និងទូទាត់ថវិកា

○រាយការណ៍ការចំណាយតាមខ្ទង់ចំណាយធំៗ(រដ្ឋបាល ការបង្រៀននិងរៀន និង បរិស្ថាន) បានប្រសើរដោយផ្តោតការចំណាយលើការបង្រៀន និងរៀន

## ៩. តម្រូវការហិរញ្ញប្បទាន( តាមឆ្នាំនីមួយៗសម្រាប់រយៈពេល៥ឆ្នាំ )

| ល.រ | សកម្មភាព | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ១ | គោលនយោបាយសាលារៀន | 56,700,000៛ | 65,296,000៛ | 71,379,000៛ | 80,062,000៛ | 90,270,000៛ |
| ២ | ពង្រឹងការងារបង្រៀន និងរៀន | 1,400,000៛ | 15,898,000៛ | 14,985,000៛ | 34,215,000៛ | 35,200,000៛ |
| ៣ | មាតា បិតានិងសហគមន៍ជួយការសិក្សារបស់សិស្ស | 1,200,000៛ | 1,200,000៛ | 3,500,000៛ | 3,300,000៛ | 1,000,000៛ |
| ៤ | សិស្សនិងសេវាជួយសិស្ស | 0 ៛ | 1,000,000៛ | 3,000,000៛ | 1,000,000៛ | 2,000,000៛ |
| ៥ | ការងារដឹកនាំនិងគ្រប់គ្រង | 2,700,000៛ | 6,736,000៛ | 12,573,500៛ | 8,926,000៛ | 5,500,000៛ |
| ៦ | ធនធានមនុស្ស | 0 ៛ | 700,000៛ | 700,000៛ | 2,300,000៛ | 1,000,000៛ |
| ៧ | សម្ភារបង្រៀន និងរៀន | 300,000៛ | 400,000៛ | 400,000៛ | 3,200,000៛ | 4,200,000៛ |
| ៨ | កសាងហេដ្ឋារចនាសាលារៀន | 3,584,000៛ | 4,000,000៛ | 5,159,500៛ | 12,990,000៛ | 16,000,000៛ |
| ៩ | កៀរគរហិរញ្ញវត្ថុប្រកបដោយតម្លាភាព | 0 ៛ | 0 ៛ | 1,000,000៛ | 1,000,000៛ | 226,000៛ |
| ថវិកាសរុប | | 63,040,500៛ | 95,230,000៛ | 112,697,000៛ | 146,993,000៛ | 155,396,000៛ |

## ១០. យន្តការពិនិត្យតាមដាន និងវាយតម្លៃ

យន្តការពិនិត្យតាមដាន និងវាយតម្លៃ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ត្រូវបានពិនិត្យរួមគ្នាជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន **លើដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន** និងរៀបចំចំណាយថវិកាតាមគណនីសម្រាប់មូលនិធិកម្រិតសាលារៀន ថវិកាកម្មវិធី និងប្រភពផ្សេងៗទៀតនៃមូលនិធិ ដូចជា ថវិកាកែលម្អសាលារៀន វឌ្ឍនភាពនៃការពិនិត្យតាមដាន និងរៀបចំរបាយការណ៍វឌ្ឍន៍ភាព សម្រាប់ការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌ ។

## ១១.តារាងឧបសម្ព័ន្ធ

| ល.រ | សកម្មភាព | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| 1 | ចំនួនសិស្សថ្នាក់ទី៧ | 204 | 189 | 170 | 193 | 220 |
| 2 | ចំនួនសិស្សថ្នាក់ទី៨ | 145 | 139 | 134 | 135 | 180 |
| 3 | ចំនួនសិស្សថ្នាក់ទី៩ | 112 | 128 | 101 | 118 | 124 |
| 4 | ចំនួនសិស្សថ្នាក់ទី១០ | 212 | 264 | 293 | 297 | 355 |
| 5 | ចំនួនសិស្សថ្នាក់ទី១១ | 166 | 137 | 196 | 224 | 250 |
| 6 | ចំនួនសិស្សថ្នាក់ទី១២ | 111 | 143 | 120 | 166 | 210 |
| 7 | ចំនួនគ្រូបង្រៀន សរុប: 45 នាក់ | | | | | |
| | ស្រី : 18 នាក់ | | | | | |
| 8 | ចំនួនអគារសិក្សា | 3 | 3 | 3 | 3 | 3 |
| 9 | ចំនួនបន្ទប់ | 15 | 15 | 28 | 28 | 28 |
| 10 | ចំនួនថ្នាក់ | | | | | |
| 11 | តម្រូវការថវិកាសរុប | 63,040,500៛ | 95,230,000៛ | 112,697,000៛ | 146,993,000៛ | |

ថ្ងៃ..................ខែ...............ឆ្នាំកុរ ឯកស័ក.ពស២៥៦៣

ធ្វើនៅ............ ថ្ងៃទី..........ខែ.................ឆ្នាំ ២០១៩

**នាយកសាលា**

ថ្ងៃ..................ខែ.................ឆ្នាំកុរ ឯកស័ក.ពស២៥៦៣

ធ្វើ............ ថ្ងៃទី..........ខែ.................ឆ្នាំ ២០១៩

បានឃើញ និង ពិនិត្យត្រឹមត្រូវ

**ប្រធានគណៈកម្មការគ្រប់គ្រងសាលា**

បានឃើញ និងឯកភាព

ថ្ងៃ..................ខែ.................ឆ្នាំកុរ ឯកស័ក.ពស២៥៦៣

.....................ថ្ងៃទី.........ខែ................ឆ្នាំ ២០១៩

**ប្រធានការិយាល័យអប់រំយុវជន និង កីឡា ស្រុក**